# ជំពូក

# ស្នាមសាក់លើកញ្ចឹងក

អូហូ! នេះឯង ទីក្រុងភ្នំពេញ! រាជធានីមួយដែលល្បីថា មានភាពស៊ីវិល័យនិងសកម្មភ្លៀវភ្លា មមាញឹក។

ទោះយ៉ាងណា សម្រាប់មនុស្សដូចគេនេះ ទីក្រុងគង់សឹងគ្មានអ្វីដែលមើលទៅគួរឱ្យចាប់អារម្មណ៍ ជាជាងព័ត៌មានអំពីស្រីស្អាតៗនៅក្លឹបរាត្រីល្បីៗឡើយ។ រឿងដែលគួរឱ្យរំខានមួយទៀត គឺគេមិនចូលចិត្តពាក្យពីរម៉ាត់«ប៉ូលិស»។

អារម្មណ៍មិនសុខស្រួលទេ នៅពេលដែលចេញឆ្ងាយពីដែលនិរតីមកភ្នំពេញ គឺតែងតែញ៉ាំងឱ្យគេធ្វើមុខមាំ ដើរញាប់ៗ មិនងាកសម្លឹងអ្នកណាទាំងអស់ ធ្វើដូចពិភពលោកនេះមិនមានអ្នកណាសំខាន់សម្រាប់គេ មិនមានសាច់រឿងណាមួយដែលគេចង់ដឹង ថែមទាំងគេគ្មានការចងចាំឬអនុស្សាវរណាទាំងអស់នៅកន្លែងនេះ ទីក្រុងមួយនេះ។

កាត់តាមរបៀងអាគាររចនាលម្អអមដោយសាលវិចិត្រនា ដែលចម្រុះទៅដោយពន្លឺអំពូលប្រណីតភាពពណ៌មាសនិងប្រាក់លាយគ្នានេះជាទម្រង់នៃសណ្ឋាគារដ៏ធំនាំគេឱ្យចាប់ផ្តើមមានអារម្មណ៍ថា«វង្វេង»។

ជាមួយនឹងបំណែកខណ្ឌចែកអាគារទៅជាច្រើនផ្នែក ទីនេះមិនមែនងាយស្រួលសម្រាប់មនុស្សទើបមកដល់ភ្នំពេញដូចជាគេ ក្នុងការឆ្ពោះទៅរកគោលដៅទេ។

ដោយសារការតុបតែងមានលក្ខណៈស្រដៀងគ្នាផង និងច្រើនរបៀងខ្វាត់ខ្វែងផង។ ទូរសព្ទគេរោទ៍តែគ្មានសំឡេងមានតែរំញ័រ....គេទាញវាចេញពីហោប៉ៅមកស្តាប់ដោយយកចិត្តទុកដាក់។

«ជម្រាបសួរប៉ា!»

«រឿងខូចការហើយកូន!»

គេរេគ្រាប់ភ្នែកតែបន្តិចប៉ុននោះ បង្ហាញនូវសញ្ញាធូរចិត្តនៅក្នុងបេះដូងដ៏ស៊ីជម្រៅ ប៉ុន្តែទឹកមុខគេមិនប្រែប្រួលនោះទេ។ ជាផ្ទៃមុខដ៏រឹងមាំនៃបុរសម្នាក់ ដែលជាតួឯកធំនៅក្នុងសាច់រឿងរបស់យើង។

«ផែនការត្រូវបែកការណ៍!»

សំឡេងឪពុកប្រាប់មកបន្ថែម ទាំងដែលបបូរមាត់អ្នកខាងណោះមិនទាន់ទាំងបានសួរផងថា អ្នកណាជាអ្នករាយការណ៍ទៅប៉ូលិស? អ្នកណាទៅ នៅមិននៅមកលូក រករលាកភ្លើងដោយថ្លើមពាសមេឃ ហ៊ានមកឈររារាំងខូចការងារដែលជាដើមចមក្នុងការឱ្យប៉ាបញ្ចេញសព្ទសំឡេងខូចចិត្តមួយដែលគេមិនធ្លាប់ឮពីមុនមក។

«រឿងមួយទៀតកូន!»

សម្ដីឪពុកលាន់មកបន្ថែមទៀតធ្វើឱ្យគេមានអារម្មណ៍ថា ក៏សំខាន់មិនចាញ់គ្នានឹងរឿងកំពុងខូចចិត្តមុននេះនោះឡើយ។

«បាទប៉ា...?»

គេសួរខ្លីទៅតាមទម្លាប់ដែលកម្រនឹងនិយាយច្រើន។

«ប្អូនប្រុសរបស់ឯង......»

បុរសតបតិចៗហាក់យល់ន័យអ្វីដែលឪពុកកំពុងនិយាយ

«ចាំខ្ញុំនាំគេត្រលប់ទៅវិញ!»

តាមពិតទៅ កាលដែលគេកំពុងបោះជំហានចូលមកក្នុងបរិវេណនៃកន្លែងមួយដែលគេ តាមថា «មិនចង់មក»នេះ មកតែពីកំពុងស្វែងរកប្អូនប្រុសគេ។ បបូរមាត់ក្រាស់ គ្មានស្នាមញញឹម និយាយបន្ថែមជូនទៅកាន់អ្នកមានគុណ៖

«ខ្ញុំកំពុងតាមរក Yusu ខ្ញុំនាំគេទៅកោះវិញឥឡូវនេះហើយប៉ា!»

ប៉ុន្តែការពិតគឺលើសពីហ្នឹង។ អ្នកជាឪពុកវិញយល់ថា ជាពេលគួរប្រាប់គេ និងផ្ដល់ព័ត៌មានទាំងអស់ឱ្យច្បាស់ៗ ដូច្នេះមុនពេលគេចង់បិទទូរសព្ទ ស្រាប់តែសំឡេងគាត់លាន់មកបន្ថែម៖

«ឥន្ទ្រា! ស្ដាប់....»

ជំហានគេប្រុងបោះទៅមុខទៀត ក៏ត្រូវនៅស្ងៀមជាមួយនឹងសូរសព្ទយ៉ាងសំខាន់របស់ឪពុក។

«សង្សាររបស់ Yusu ជាអ្នករាយការណ៍រឿងទាំងអស់របស់យើងទៅប៉ូលិស! ក្មេងស្រីនោះ ប្រហែលជាបានស្ទែនទិន្នន័យទាំងអស់ពីទូរសព្ទប្អូនប្រុសឯង!»

គេងើបមុខយឺតៗបង្ហាញនូវចិញ្ចើមវែងក្រាស់និងកែវភ្នែកដ៏កំណាច ប្រៀបបានទៅនឹងចិញ្ចើមស្ដេចនាគដែលលម្អដណ្ដប់ពីលើពន្លឺនៃត្រាដូចពពួកម្រឹគ។

ឥន្ទ្រាជាឈ្មោះរបស់គេ។ ប្រុសនេះរវៀកសម្លឹងមើលមួយជុំខ្លួន។ ទោះបីឃើញហើយថាគ្មាននរណានៅក្បែរៗក៏គេនៅតែប្រុងប្រយ័ត្ន។

ឆ្ងាយពីកន្លែងនេះប្រមាណជា២០ម៉ែត្រ អ្នកបម្រើសណ្ឋាគារពីរនាក់យាត្រាញាប់ជើងជាមួយថាសភេសជ្ជៈកាត់ពីរបៀងខាងកើតឆ្ពោះទៅខាងលិច សូម្បីតែឆ្ងាយពីគេយ៉ាងនេះ ឥន្ទ្រានៅតែដកថយខ្លួនមកសំងំក្បែរជញ្ជាំងដើម្បីស្ដាប់ឪពុកឱ្យកាន់តែច្បាស់។

«មិញ....ប៉ាមានប្រសាសន៍ថាម៉េច?!»

«យូស៊ូ ប្អូនប្រុសរបស់ឯងជាអ្នកនាំរនុកក្នុងរបស់ប៉ូលិសចូលសម្បុក! ព្រឹកមិញ ការងារយើងជាមួយពួកថៃ ខូចការបានដោយសារនាងម្នាក់នោះ! ហ៊ឹម លុយយើងរាប់សិបលានរលាយដូចអំបិលត្រូវទម្លាក់ទៅក្នុងសមុទ្រ!»

ប្រុសមុខស្មើម្នាក់នេះ គេនៅស្ងៀម តែប្រែថ្ពាល់ទាំងសងខាងមកជាស្លេកស។ ហេតុតែគ្មាននរណានៅទីនេះ នៅជិតក្បែរគេ បានជាមិនអាចដឹងបានថា ភ្នំភ្លើងកំពុងតែបង្កជារងើកក្ដៅឡើងៗនៅក្នុងកែវភ្នែកទាំងគូរបស់គេ។

សំណួរដំបូងលាន់ចេញពីចរន្តគំនិតគេគឺ ៖

«មនុស្សស្រីនោះជាអ្នកណា? ឈ្មោះអី?....ថ្លើមនាងធំប៉ុនណាទៅ?»

តែគេមិនបាននិយាយលាន់មាត់ទេ។ សង្ស័យប្អូនប្រុសគេមានច្រើនណាស់។ កន្លងមក ប្អូនប្រុសគេជិះមកភ្នំពេញ ដូចជាជិះអូប័រចេញចាប់ត្រីលេងក្បែរផ្ទះដូច្នោះដែរ ។

«ខ្ញុំនឹងចាត់ការពួកនោះ!» គេនិយាយខ្លីៗ ហើយហាក់មិនអស់ចិត្តគេក៏បន្ថែម

«ខ្ញុំនឹងរកមនុស្សស្រីម្នាក់នោះឱ្យឃើញ!»

«រក Yusu ឱ្យឃើញសិន! យកប្អូនរបស់ឯងមកផ្ទះឱ្យប៉ាសិន! សុវត្ថិភាពប្អូនឯង ជាអាទិភាពឥន្ទ្រា! រឿងផ្សេង ចាំមកដលកោះហើយចាំគិត»

គេងើបមុខម្ដងទៀតសម្លឹងត្រង់ភ្លឹងទៅគោលដៅច្រករបៀងដ៏ធំនិងខ្វាត់ខ្វែង។ មិនថាលោកនេះធំនិងអាថ៌កំបាំងយ៉ាងណាចំពោះគេ អ្នកណាក្ដីដែលមកកូរកកាយការរកស៊ីរបស់គ្រួសារគេនឹងមានរឿងជាមួយគេអាចជារឿងធំ។

ប្រុសបោះដំណើរតម្រង់ទៅសាលធំមួយដែលមើលពីនេះទៅឃើញមានរចនាផ្កាភ្ញី ទំនងថានៅពេលមិនយូរប៉ុន្មានខាងមុខនឹងមានកម្មវិធីធំរៀបចំឡើងនៅកន្លែងនោះ។

មនុស្សពីរបីនាក់ដើរចុះឡើងចច្រប់ បញ្ជាកម្មករប្រុសៗរៀបចំសម្ភារៈបដិសណ្ឋារកិច្ចផ្សេងៗ។

ដោយពួកគេនៅឆ្ងាយពីនេះប្រមាណជាពីម្ភៃទៅសាមសិបម៉ែត្រ ប៉ុន្តែប្រុសនៅតែមិនស្រណុកចិត្តនៅក្នុងករណីឱ្យអ្នកណាម្នាក់បានងាកមកចាប់អារម្មណ៍ប្រទះឃើញគេនោះទេ។

នៅពេលដែលឪពុកដាក់ទូរសព្ទចុះ គេចាប់ផ្តើមងាកប្តូរទិសទៅឆ្វេងដៃ បត់ទៅរកបន្ទប់ទឹកសិន។ ជាទម្លាប់របស់ឥន្ទ្រានៅក្នុងការលុបលាងមុខខ្លួនឯង ខណៈពេលណាដែលគេរងការខូចចិត្តនិងមានកំហឹង គេត្រូវការពេលបន្តិច ត្រូវការទឹកត្រជាក់បន្តិចដើម្បីរម្ងាប់វា។

រុញទ្វារចូលខ្វាក.....សម្រែកមួយលាន់ឡើង អាស់....!

នារីម្នាក់ឈរចំហដើមទ្រូងនៅចំពោះមុខគេ។ ទាំងពីរកាយភាន់ភាំង ឯខាងស្រីដែលមានសម្រស់ដូចទេពធីតាអស់ពីស្រទ្បាំងកាំង នាងទាញយករ៉ូបស្បៃពណ៌សឡើងមកយ៉ាងរួសរាន់ តែទាញយ៉ាងណានៅតែមិនព្រមឡើងព្រោះមានសណ្ឋានតឹងថ្អឹះ។

ហេតុការណ៍ហួសពីការគិតទុក មិនត្រឹមធ្វើឱ្យបុរសនេះនៅគាំងចំកណ្តាលមាត់ទ្វារ ដែលរបើកចូលមកស្ទាក់ស្ទើរ គេសម្លឹងផ្ទាំងនឹងទឹកមុខរបស់នាងដែលក្រហមដោយក្តីខ្មាសលាយខឹងសម្បា។

ពេលស្រីខំទាញរ៉ូបមកបិទបាំងដើមទ្រូងមិនបានទាន់ចិត្ត នាងប្រញាប់បែរខ្នងគេចចេញបង្ហាញសណ្ឋានសាច់សរលោងនៃកាយអាក្រាយល្វែងខាងលើផ្នែកខាងក្រោយឱ្យបុរសនេះមើលបានពេញភ្នែក។

«អត់ស្គាល់បន្ទប់ទឹកស្រីទេ?»

នាងស្រែកខឹងឡើងទាញពញ្ញាក់ការស្លុងស្លឹកមុខរបស់នាយ ហើយកើតក្តីហួសចិត្តដែលខ្លួនត្រូវក្រពុលមុខព្រោះដំណឹងមិនល្អពីដែនកោះ រហូតដល់ដើរចូលបន្ទប់ស្រីទាល់តែបានមែន។

បន្ទប់ភេទទាំងពីររៀបចំដូចគ្នាពេកហើយ សូម្បីតែរូបសម្គាល់ថាបន្ទប់ទឹកប្រុសឬស្រីក៏តូចសែនតូចថ្នាក់គេភ្លាត់បាន។ មិនអាចប៉ះប៉ូវអ្វីបាន មានតែទាញបិទទ្វារវិញគ្រា ហើយដើរចេញមករឹង។

.....មានអារម្មណ៍ថាថ្ងៃនេះគ្រប់យ៉ាងដូចជាអន្ទះសាជាខ្លាំង ហើយជួបរឿងចម្លែកបន្តិចមែនសម្រាប់គេ។ ទូរសព្ទរោទ៍ឡើងទៀត បុរសរៀបលូកដៃយកឡើងមកអាន គិតថាជាឪពុកដែលផ្តាំមិន

ទាន់បានចប់ តែមិនទាន់បានទទួលផង ស្នូរសំឡេងរងំមកតាមពីក្រោយ.....ទាញយកស្មារតីប្រុងប្រយ័ត្នរបស់គេ។

ជាមួយក្តីងឿងឆ្ងល់ គេមិនទាន់លើកនៅឡើយដ្បិតត្រូវងាកក្រោយសម្លឹង....ថាតើសម្រិបជើងអ្វីអន្ទោលតាមប្រាណនេះ....តាមពិតក្រឡេកទៅស្គាល់ថាជាម្នាក់ស្រីរ៉ូបអម្បាញ់មិញ ធ្វើឱ្យចិត្តបុរសទៅជាស្រទន់ខ្សាំងកាំងម្តង។

នាងគ្មានស្បែកជើងនោះទេ ប្រហែលជានាងរួសរាន់ពេកនៅក្នុងការរត់ចេញមកប្រដេញតាមពីក្រោយនាយ ថែមស្រែកហៅនាយចំៗ....

«ឈប់! អេ្ហ៎ ឮឱ្យឈប់?» គឺហៅយ៉ាងទ្រគោះ ព្រោះនាងខឹង។

ដែលកាន់តែអស្ចារ្យបំផុត គឺនៅលើដៃនាងមានថូផ្កាមកតាមមួយផងទាស់ត្រង់គ្មានផ្កាទេ មានតែទឹកកន្លះថូគ្រីស្តាល់.....

រាងកាយមនុស្សប្រុសនៅទ្រឹងភាន់ ព្រោះឃើញស្រីឱបអាវរ៉ូបស្បែសត្រឹមទ្រូងហើយរត់ប្រដេញមក បានជាគេមិនឈានទៅណា ស្រាប់តែនេះជាឱកាសឱ្យនាងប្រើដៃតែម្ខាងដែលនៅសល់លើកថូគ្រីស្តាល់ជះមកចំកណ្តាលមុខរកគេចទៅណាមិនរួច.....

«សុំទោស មួយម៉ាត់ក៏មិនចេះនិយាយ! មនុស្សព្រៃ!»

នាងថាឱ្យខ្លាំងៗទាំងខាំមាត់ធ្វើមុខកាចមុតៗ សម្លឹងភ្លឺផ្លេកៗទៅកាន់មនុស្សប្រុសដែលកំពុងលើកកំភួនដៃស្តាំមកជូតមុខសន្សឹមៗ។

ដៃគេទម្លាក់ចុះមកបញ្ចេញនូវវង់ភក្ត្រកាចៗសម្លឹងនាងមុតៗវិញ។ កូនប្រុសច្បងរបស់មហាសេដ្ឋីដីកោះ គេធ្លាប់និយាយសុំទោសអ្នកណាទៅ? សូម្បីតែទៅរៀនក៏គេមិនដែលទៅផង គេចេះគួរសមពីណាមក? សូម្បីស្រឡាញ់ស្រីក៏ពាក្យនេះគេមិនដឹងមានន័យអ្វីឡើយ តើគេចេះផ្អែមល្ហែមជាសុភាពបុរសម្តេចបាន?

ឆាកជីវិតមួយជាដៃស្តាំរបស់ឪពុក បោះពួយបត់បែនអូរប័រលើផ្ទៃសាគរ និងជិះតែឧទ្ធម្ភាគចក្រច្រើនជាងដើរដី តើគេទទួលយកពាក្យដៀលថា«មនុស្សព្រៃ»បានដែរឬយ៉ាង?

មួយឆ្នាំៗ គេមិនទាន់និយាយគ្រប់៣៦៥ពាក្យផង គេមិនទៅមកជួបជាមួយមនុស្សចម្លែកណាម្នាក់ទេ ជីវភាពរបស់គេគ្មានទេពាក្យថា«អរគុណ»ឬ«សុំទោស» នាងជាអ្នកណាចង់មកទាមទារពាក្យនេះពីគេ?

ជាមួយទឹកមុខកាចៗលាយឡំនឹងភាពហួសចិត្តនៅក្នុងបេះដូងមួយដែលកំដរឱ្យឆាកជីវិត ដែលតែងមានមនុស្សឱនលំទោនដាក់ ស្រាប់តែពេលនេះ ថ្មើរណោះ មកត្រូវមនុស្សស្រីសំគមម្នាក់ រត់ប្រដេញមក ថែមទាំងជះទឹកកខ្វក់សល់ពីដើមផ្កា ជំក្លិនស្អុយគគ្រុកចំកណ្តាលមុខទៀត?

ខណៈពេលដែលនាងលើកដៃចង្អុលមុខនាយចំៗនិងព្រមាន «កុំឱ្យខ្ញុំឃើញមុខឯងទៀត!» គេក៏មិនយល់ដែរថា កាលដែលគេបានឃើញដើមទ្រូងនាងអម្បាញ់មិញតើជារឿងធំប៉ុនណាទៅ? សម្រាប់គេវាគ្មានន័យអីទាំងអស់ វាជារឿងតូចមួយប៉ុននោះ តើរូបរាងមនុស្សស្រីបែបណាដែលគេមិនធ្លាប់ឃើញប្រសិនគេចង់?

ឥន្ទ្រាគេក្តាប់មាត់ប្រុងធ្វើអ្វីម្យ៉ាងខណៈពេលដែលស្រីល្អិតបែរខ្នងដើរចេញមួយៗ ប៉ុន្តែ....

«ថៅហ្វាយ!»

បុរសម្នាក់បង្ហាញខ្លួនរត់ផង ដើរផងយ៉ាងញាប់មកពីទិសខាងត្បូង។

ឥន្ទ្រាឈប់ដំណើរ លែងផ្តោតលើស្រ្តីរូបស ព្រោះអ្នកដែលទើបមកដល់តាមពិតជាដៃស្តាំរបស់ឪពុកគេ។ គាត់ឈ្មោះ Bill តែជាជនជាតិខ្មែរមានឈ្មោះបរទេស ព្រោះពួកគេនិយមប្រើរហ័សនាមឬឈ្មោះបស្ចិមប្រទេសមកហៅគ្នា ជំនួសឱ្យឈ្មោះដើមដែលឪពុកម្តាយដាក់ឱ្យ។

លើកលែងតែគាត់មានរឿងសំខាន់បានគាត់រត់មកក្នុងសភាពប្រញិបប្រញាប់បែបនេះ។

«សូមថៅហ្វាយជួយទៅមើលសាលទីប្រាំផង! ខ្ញុំដោះស្រាយមិនចេញទេ!»

ជននេះមកដល់ទាំងហត់ដង្ហក់ហើយហាក់ចាប់អារម្មណ៍នឹងសភាពទទឹកពាសពេញមុខមាត់របស់ឥន្ទ្រា។ គាត់សម្លឹងមករហូតដល់កអាវគេដែលដាមស្នាមទឹកដោយអន្លើដែរ។

មិនដឹងថា ការខាតបង់លុយរាប់សិបលានដុល្លារកាលពីព្រឹក ពិតជាធ្វើឱ្យបុរសក្មេងត្រូវស្រ្តេសដល់ថ្នាក់ទៅឱនងូតទឹកលុបមាត់ទទឹកពាក់កណ្តាលកាយបែបនេះ?

គាត់លូកកន្សែងដៃខ្លួនហុចឱ្យ។ ពេលគេកំពុងជូតមុខគាត់ខ្សឹបប្រាប់៖

«លោកយូស៊ូកំពុងតែ.....ហ៊ឹម! ខ្ញុំឃាត់គាត់មិនជាប់ទេ.....គាត់កំពុងតែ....»

គេទប់ដៃ រវៃ្នកសម្លឹងមុខបុរសនេះ។ មិនចាំបាច់ឱ្យពូ Bill និយាយបញ្ចប់នោះទេ គេសួរកាត់៖

«សាលលេខ៥ហ្នឹងស្អីគេ?»

គាត់ធ្វើដៃជាសញ្ញានាំផ្លូវជំនួសចម្លើយ។ ឥន្ទ្រាបោះជំហានវែងៗ មួយៗដោយយកចិត្តទុកដាក់សំដៅទៅសាលទីប្រាំ។ ទីនេះពិតជាឋានសួគ៌ក្រោមមេឃ ជាមួយនឹងបទភ្លេងយុវវ័យប្រគំរណ្ដំស្វាគមន៍មកពីចម្ងាយ។

ក្រោមរលកពន្លឺភ្លើងឆ្វេចឆ្វាចសែនស៊ីវិល័យ គ្មានអ្នកណានៅទីនេះមកខ្វល់ខ្វាយអំពីដំណើរមុខមាំ ឆ្មើងកន្ទ្រើងកម្ពស់ដ៏ខ្ពស់របស់គេ និងរាងស្គមស្ដើងរហ័សរហួនម្នាក់នេះនៅឡើយទេ។

រូបរាងរបស់គេសាមញ្ញពេកហើយនៅក្នុងការឱ្យមនុស្សម្នានៅទីនេះងាកមកចាប់អារម្មណ៍ ជាពិសេសមុខមាត់ត្រឹមត្រង់ មិនមានស្នាមញញឹម ឬកពា ថ្ងាសជ្រួញចូលគ្នាដូចជាចាស់ទុំជាងវ័យបង្ហាញថាគេមិនសមជាយុវវ័យដែលចូលមកលេងកន្លែងនេះទេ។

ដូចគ្នា! គេក៏មិនខ្វល់ចំពោះអ្នកណាគិតអំពីគេបែបណាដែរ។

នៅលើឆាក! មនុស្សនៅលើឆាកទើបជាអ្វីដែលគេចាប់អារម្មណ៍។

«យូស៊ូ?»

គេភ្លាត់មាត់តិចៗខណៈកែវភ្នែកមុតសឹងចេញផ្សែងសម្លឹងផ្ដោតទៅប្អូនប្រុសដ៏ស្រស់សង្ហាកំពុងតែសើចក្អាកក្អាយកាច់កកាច់ស្រង់នៅកណ្ដាលឆាក ដៃកាន់លើកដបស្រាដ៏មានតម្លៃ បាញ់រេ ជះពាសពេញទៅកាន់ក្រុមអ្នករាំ.....

«ផឹកទៅផឹកទៅ! ផឹកឱ្យអស់ស្រាក្នុងស្តុកនេះម្តងមើល៍ ចាំមើល៍ គេបានស្រាអីមកលក់ឱ្យយើងទៀត!»

កាយវិការចំណាយដ៏ខ្ជះខ្ជាយនេះ កំពុងធ្វើឱ្យក្មេងស្រីជំទង់នានានៅជុំវិញនោះស្រែកហ៊ោរកញ្ជ្រៀវដោយសេចក្តីសោមនស្សស្រវឹងក្តីត្រេកត្រអាលរីករាយ។

មនុស្សប្រុសពីរនាក់ស្ទុះមកអមឥន្ទ្រាទាំងសងខាងស្មា។ ក្នុងនោះមានម្នាក់វ័យក្មេងល្ហក់ ហាឡើងទាំងញ័រដៃ៖

«បង! បងឥន្ទ្រា! បងយូស៊ូស្រវឹងពោបហើយ អាចនឹងដួលកណ្ដាលចំណោម!»

ប្រុសជារៀមច្បង ធ្វើមុខមាំ។

សភាពទ្រហឹងនៅទីនេះ រួមនឹងស្រមោលនៃមមាចមិនស្គាល់ភ្លើងអស់ទាំងនេះ បង្កឱ្យទ្រូងគេធុញពេកទៅហើយ ចំណែករូបភាពប្អូនប្រុសគេ កំពុងអាវ៉ាសែបែបនេះទៀត គេទប់ចិត្តលំបាកក្រៃលដែរ ក្នុងការចេញបទបញ្ជាធម្មតាស្មើៗ៖

«យកវាចេញមក! អាយូស៊ូ!»

«មិញ ឡើងទៅពីរនាក់ហើយ ឡើងពីរដងហើយទានគាត់ច្រានដួលទាំងអស់ គ្មាននរណាហ៊ានទេ គាត់ព្រមានវាយក្បាលនឹងដបស្រា!»

ស្ដាប់ពាក្យពួកគេរាយការណ៍ធ្វើឥន្ទ្រាហួសចិត្ត។

គេច្រត់ចង្កេះក្តាប់មាត់ដកដង្ហើមវែងៗ ពីព្រោះធាតុពិត គេមិនចង់ប៉ះពាល់ជាមួយលើរង្វង់រាំដ៏ធំកកកុញទៅដល់យុវវ័យដែលកំពុងតែបិទភ្នែកភ្លើតភ្លើននៅក្រោមចង្វាក់ភ្លេងស្រើបស្រាលនោះទេ ប៉ុន្តែនៅក្រោយពីរដង្ហើមប៉ុននោះគេចាំបាច់ត្រូវធ្វើសកម្មភាព.....

ប្រុសឈានជើងវែងៗចូលទៅសំដៅឆាកដែលមានរាងជារង្វង់មូល។ មនុស្សម្នាផ្ដើមសម្លឹងនិងយកចិត្តទុកដាក់ចំពោះគេ ពេលគេចូលមកក្បែរយូស៊ូ

«ទៅផ្ទះវិញ!»

ឥន្ទ្រានិយាយខ្លីៗមិនចង់និងគ្មាននរណាឮនោះទេ ឯប្អូនប្រុសគេក៏ប្រហែលជាមិនឮដែរ ព្រោះកំពុងតែស្រវឹងដាប ហើយសប្បាយរីករាយនឹងការចាក់ស្រាបង្ហិន។ នៅពេលដែលបងប្រុសប្រើដៃម្ខាងកាន់កដៃគេនិងដៃម្ខាងទៀត ដកយកដបស្រាពីគេ គេបួងដៃស្ដាំឡើងមកប្រុងបុកសំដៅមុខទៅហើយ ប៉ុន្តែគ្រាន់តែក្រឡេកឃើញថាជាបងប្រុស ក៏បង្អង់ដៃទម្លាក់ចុះវិញហើយធ្វើមុខខ្សោយៗ.....

ឥន្ទ្រាក្តាប់មាត់រង្កើក្រញាំចង្កាតិចៗ ចំពោះកែវភ្នែកទុកព្រួយរបស់ឯយូស៊ូ។ បុរសជាប្អូនឈប់ចលនាក្រោកឈរត្រង់ខ្លួនវិញសន្សឹមៗហើយបង្ហាញអាការៈទុក្ខព្រួយតបនឹងវត្តមានបងប្រុស។

«បង!.....បងឥន្ទ្រា.....ខ្ញុំស្លាប់ហើយបង!.....ខ្ញុំកំពុងស្លាប់! បងឃើញទេ មនុស្សអន់ដូចខ្ញុំ! ស្រីបោកខ្ញុំណាបង! វាបោកបេះដូងប្អូនបងឯង!»

គ្មានប្រតិកម្មថ្មីលើផ្ទៃមុខទេ ឥន្ទ្រានិយាយតិចៗដោយបែរខ្នង ឯហត្ថាគេនៅតែចាប់ទាញប្អូនប្រុសយកមកតាម៖

«ទៅផ្ទះវិញជាមួយបង!»

គេនិយាយខ្លីៗ មិនខ្វីមើលមុខញ្ញែកមាយារបស់ប្អូនប្រុសម្នាក់នេះ។ ដោយត្រូវបងទាញអូសដៃចេញទៅ គេក៏នៅឆ្លើយលើកដៃស៊ីញ៉ូលេងដាក់ក្រុមយុវវ័យទាំងឡាយកំពុងចាប់អារម្មណ៍ជាមួយនឹងសកម្មភាពឆ្កួតលីលារបស់គេ។

«ចួបគ្នាថ្ងៃក្រោយណ៎ា!»

«បងយូស៊ូ! អ្នកណាហ្នឹង អង្គរក្សថ្មីហ្មែនសង្ហាម៉េះ? ទាស់មុខកាចបន្តិច!»

ខ្លះក៏តាមមើល ខ្លះថតដាក់ទូរសព្ទ ខ្លះសើចចំអកឡកលើយនិងខ្លះទៀតភ័យថយញ្ញែកផ្លូវឱ្យ។

សំឡេងស្រីៗលាន់មកពីក្នុងក្លឹបល្វើយៗ៖

«ម្នាក់មិញ បងយូស៊ូឬមួយអង្គរក្សយូស៊ូ?»

«អ្ហួយចាប់អារម្មណ៍អត់? គេមានស្នាមសាក់មួយលើគល់ក សង្ហា!»

យូស៊ូនៅឆ្លៀតបែរក្រោយពេលឮបែបនេះ ក៏បកបែរក្រោយស្រែកប្រាប់ពួកនាងទាំងញញឹម៖

«សាក់រូបក្អែកខ្មៅ ឡូយទេ? សាហាវអត់! បងក៏មានសាក់ដែរ តែសាក់នៅក្រោមចង្កេះចង់ឃើញដែរ?»

ឥន្ទ្រាកញ្ឆក់ដៃទាញប្អូនចេញវឹង ទាំងមិនងាកឆ្វេងមិនងាកស្តាំព្រោះគេដឹងថា យូស៊ូបាត់សតិប្រមាណ៩០ភាគរយហើយ បណ្តោយតែបន្តិចទៀត សូម្បីកម្លាំងដើរក៏ប្រហែលជាលែងមានដែរ មានតែត្រូវឱ្យគេនេះលីប្អូនឡើងទៅលើឧទ្ធម្ភាគចក្រ?